ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍ក្របីរៀល

## រយៈពេល ០៣ឆ្នាំ
## ២០២០-២០២២

កន្លែងនេសាទសហគមន៍ ៖ ក្របីរៀល

ភូមិ ៖ ត្រពាំងវែង

សង្កាត់៖ ក្របីរៀល

ក្រុង ៖ សៀមរាប

ខេត្ត ៖ សៀមរាប

**មាតិកា**

**ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍**


**១. ស្ថានភាពទូទៅ** ........ ១

**២. អំពីប្រជាសាស្ត្រ** ........ ២

ក-ប្រជាពលរដ្ឋ ........ ២

ខ-មុខរបរ ........ ២

**៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍**

ក- ទីតាំងភូមិសាស្ត្រ និងព្រំប្រទល់ ........ ២

ខ- ដែននេសាទ ........ ៣

គ- តំបន់មានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ........ ៣

ឃ- ធនធានជលផល ........ ៤

**៤. ការធ្វើនេសាទ** ........ ៦

ក- អ្នកនេសាទ ........ ៦

ខ- ឧបករណ៍នេសាទ ........ ៦

គ- ប៉ាន់ប្រមាណផលនេសាទប្រចាំឆ្នាំ ........ ៨

**៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍** ........ ៨

ក- ទស្សនៈវិស័យ ........ ៨

ខ- គោលបំណង ........ ៨

គ- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ ៩

គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ ........ ៩

គ២-ផែនការកែលម្អដែននេសាទ ........ ១០

គ៣-ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ........ ១០

គ៤-ផែនការគ្រប់គ្រងព្រៃលិចទឹក ........ ១១

គ៥-ផែនការអភិរក្សវារីវប្បកម្ម ........ ១១

គ៦-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ........ ១២

គ៧-ផែនការផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ ........ ១២

ឃ- យុទ្ធសាស្ត្រ ........ ១៣

-តារាងសង្ខេបផែនការ ........ ១៥

-តារាងកម្មវិធីការងារ ........ ១៨

# ផែនការគ្រប់គ្រងកន្លែងនេសាទ
# សហគមន៍ក្របីរៀល

**១ ស្ថានភាពទូទៅ**

សហគមន៍នេសាទក្របីរៀល បានបង្កើតឡើងដោយមហាសន្និបាតកំណើតដំបូងលើកទី១ នៅឆ្នាំ២០០១ ដោយមានការសហការរៀបចំពីអាជ្ញាធរដែនដី ជំនាញជលផលព្រមទាំងមានការគាំទ្របច្ចេកទេសពីគម្រោងការចូលរួមគ្រប់គ្រងធនធានធម្មជាតិតំបន់បឹងទន្លេសាបប្រចាំខេត្តសៀមរាប និងលើកទី២នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៦ ដោយមានការជួយឧបត្ថម្ភពីគម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប-ផ្នែកទី២ ហើយគម្រោងបានដំណើរការធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៧។

សហគមន៍នេសាទក្របីរៀល មានទីតាំងស្ថិតនៅក្នុងភូមិក្រពាំងវែង សង្កាត់ក្របីរៀល ក្រុងសៀមរាប ខេត្តសៀមរាប។ មានប្រជាជនពលរដ្ឋជាសមាជិកសហគមន៍ចំនួន ១២១៨គ្រួសារ ហើយបានចុះឈ្មោះជាសមាជិកភាពចំនួន១៣៨៥នាក់ ក្នុងនោះមានស្រីចំនួន៣៣៦នាក់ សហគមន៍នេសាទមានរចនាសម្ព័ន្ធដឹកនាំដោយគណៈកម្មការចំនួន១១ នាក់ ក្នុងនោះមានស្រី ២ នាក់។

ដោយមានការជួយគាំទ្រពីគម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប-ផ្នែកទី២ សហគមន៍នេសាទបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួនមានដូចជាៈ

-រៀបចំចងក្រងរចនាសម្ព័ន្ធសហគមន៍នេសាទ តាមរយៈការអប់រំបណ្តុះបណ្តាលដល់គណៈកម្មការសមាជិកសហគមន៍ និងអ្នកពាក់ព័ន្ធ ដើម្បីបង្កើនសមត្ថភាពយល់ដឹងអំពីការគ្រប់គ្រងសហគមន៍នេសាទ។ ជាអាទិ៍មានការផ្តួចផ្តើមគំនិត និងវាយតម្លៃទីតាំងបង្កើតសហគមន៍ និងបទបញ្ជាផ្ទៃក្នុង ការរៀបចំមហាសន្និបាត ការកំណត់ព្រំប្រទល់សហគមន៍នេសាទ ការចុះកិច្ចព្រម ព្រៀងកន្លែងនេសាទសហគមន៍ ការចុះបញ្ជី ការទទួលស្គាល់សហគមន៍នេសាទនិងការរៀបចំផែនការគ្រប់គ្រង។

-ផ្សព្វផ្សាយលក្ខន្តិកៈតាមបណ្តាភូមិក្នុងសហគមន៍និងឃុំពាក់ព័ន្ធដែលជាប្រជានេសាទមកពីក្រៅសហគមន៍ និងចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗ និងការងារប្រជុំបណ្តាញសហគមន៍ នៅខណ្ឌរដ្ឋបាលជលផលសៀមរាប។

-ការផ្តល់ប្រតិភូកម្មអំណាចដល់សហគមន៍ក្នុងការគ្រប់គ្រងធនធានក្នុងសហគមន៍បន្ទាប់ពីការរៀបចំរចនាសម្ព័ន្ធសហគមន៍រួចមក គណៈកម្មការបានដើរតួយ៉ាងសំខាន់ក្នុងការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិក្នុងដែននេសាទសហគមន៍។ មិនតែប៉ុណ្ណោះបានបង្កើតដែនអភិរក្សនាទីព្រៃលិចទឹក ក្នុងកន្លែងនេសាទសហគមន៍ ពង្រឹងកិច្ចសហការទប់ស្កាត់ និងបង្ក្រាបបទល្មើសក្នុងដែននេសាទសហគមន៍ (ការកាប់ព្រៃលិចទឹក និងការនេសាទខុសច្បាប់) ដោយសហការជាមួយសង្កាត់នេសាទប្រចាំតំបន់ ចូលរួមសហការ ការងារជាមួយអង្គការអន្តរជាតិនានាដូចជា ADB. TSSLP. PSO ។ល។ ដើម្បីដំណើរការអភិវឌ្ឍន៍ ក្នុងសហគមន៍។

-ការគាំទ្រមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទ ជាសកម្មភាពមួយដ៏ចំបងដែលជួយពង្រឹងមុខរបរដល់ប្រជានេសាទនៅក្នុងសហគមន៍ជាពិសេសគឺ ជួយ កាត់បន្ថយលើសម្ពាធនៃការធ្វើអាជីវកម្មនេសាទហួសកំរិត។ តាមរយៈសកម្មភាពនេះ បានបណ្តុះបណ្តាលជូនដល់កសិករអំពីបច្ចេកទេស និងការធ្វើបទបង្ហាញផ្ទាល់មានៈ ការចិញ្ចឹមជ្រូក ត្រី ដាំបន្លែ។ល។ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារ ឲ្យមានការរីកចម្រើនឡើង។

## ២- អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក-ប្រជាពលរដ្ឋ

សង្កាត់ក្របីរៀលមាន១២ ភូមិ គឺ ភូមិត្រពាំងវែង ទទារ រកា ក្រសាំង ព្រៃក្រូច បឹង ប្រម៉ា ខ្លា ពពិស គោកដូង ព្រៃពោធិ និងភូមិតារស់ ប្រជាពលរដ្ឋបានស្ម័គ្រចិត្តចូលរួមជាសមាជិកសហគមន៍នេសាទទាំង១២ភូមិ មានប្រជាពលរដ្ឋសរុបចំនួន១២១៨ គ្រួសារ ដែលមានសមាជិកចំនួន ៦៩៩៦ នាក់ ក្នុងនោះមានស្ត្រីចំនួ១,៧០៤ នាក់ (ស្ថិតិឃុំ ឆ្នាំ ២០០៨) ។ ជាទូទៅប្រជាពលរដ្ឋក្នុងឃុំទាំងមូលជាជនជាតិខ្មែរ ។

ផ្អែកតាមស្ថិតិប្រជាពលរដ្ឋក្នុងសង្កាត់ បានបង្ហាញនូវកំណើនប្រជាពលរដ្ឋនៅក្នុងសង្កាត់ទាំងមូលមានការកើនឡើងជាលំដាប់។

ស្ថានភាពប្រជាពលរដ្ឋក្នុងសហគមន៍មាន :

- ស្ត្រីមេម៉ាយចំនួន ១៣៦ នាក់
- ជនពិការចំនួន ២៨ នាក់ ក្នុងនោះមានស្ត្រី ១០ នាក់
- ចាស់ជរាចំនួន ៨០ នាក់ ក្នុងនោះមានស្ត្រី ៥៣ នាក់
- កុមារកំព្រាចំនួន ៣២ នាក់ ក្នុងនោះមានស្ត្រី ១៩ នាក់
- អ្នកមានជំងឺរ៉ាំរ៉ៃចំនួន ៣៥ នាក់ ក្នុងនោះមានស្ត្រី ២៨ នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ ១០០%

ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់មានអ្នកមិនចេះអក្សរចំនួន១៩៦នាក់ ក្នុងនោះមានស្ត្រី១១៩នាក់ កំរិតថ្នាក់បឋមសិក្សាចំនួន៦១៣នាក់ ក្នុងនោះមានស្រី៤២៤នាក់ កំរិតមធ្យមសិក្សាចំនួន៥១២នាក់ ក្នុងនោះមានស្រី៣៣៥នាក់ ។

### ខ-មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍មាន:

- ធ្វើស្រែចំនួន ១៣១៩ គ្រួសារ ( លើផ្ទៃដីចំនួន ៦០១ ហិកតា )
- ធ្វើនេសាទចំនួន ៣១ គ្រួសារ
- ធ្វើវារីវប្បកម្ម ចិញ្ចឹមក្រពើចំនួន ៥ គ្រួសារ)
- ដាំបន្លែចំនួន ៣១២ គ្រួសារ
- ជាងផ្ទះចំនួន ៦៤ គ្រួសារ
- លក់ដូរ ចំនួន ១៣៣ គ្រួសារ
- កែច្នៃផលនេសាទ ១៥០ គ្រួសារ
- កម្មករចំនួន ៩៦៣ គ្រួសារ
- ចិញ្ចឹមសត្វចំនួន ៣១៤ គ្រួសារ
- សិប្បកម្មចំនួន ២១ គ្រួសារ

## ៣- កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

### ក-ទីតាំងភូមិសាស្ត្រ និងព្រំប្រទល់

ដែននេសាទកន្លែងសហគមន៍នេសាទក្របីរៀលមានការចូលរួមពីប្រជាពលរដ្ឋចំនួន១២ភូមិ ដែលមាននូវទីតាំង

ស្នាក់ការកណ្តាលស្ថិតនៅភូមិត្រពាំងវែង សង្កាត់ក្របីរៀល ក្រុងសៀមរាប ខេត្តសៀមរាប។ ដែលមានចម្ងាយ ១៨ គីឡូម៉ែត្រពីទីរួមខេត្តសៀមរាប។ កន្លែងសហគមន៍នេសាទក្របីរៀលជាផ្ទៃដីដែលបានកាត់ចេញពីឡូត៍នេសាទលេខ០៣ 100% និងផ្ទៃដីមួយចំនួនធំទៀតជាដែននេសាទសាធារណៈ។

កន្លែងនេសាទសហគមន៍នេសាទក្របីរៀលមានផ្ទៃដីចំនួន២៥៩៩ហិកតា ហើយមានកំណត់ចំណុចនិយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

សហគមន៍នេសាទក្របីរៀលមានព្រំប្រទល់ :

- ខាងជើងទល់ឡូត៍លេខ០៣ចាស់ (កែងផ្លូវទេះរហាលក្រោយនិងស្ពឹផ្ត្រ)
- ខាងត្បូងទល់នឹងបឹងទន្លេសាប
- ខាងកើតទល់នឹងចុងឃ្មៀស
- ខាងលិចទល់នឹងឃុំខ្នាត និងកែវពណ៌

ខ-ដែននេសាទ

ដែននេសាទកន្លែងនេសាទសហគមន៍ក្របីរៀលបានផ្តល់នូវលក្ខណៈងាយស្រួលដល់ការរស់នៅ និងធ្វើអាជីវកម្មនេសាទរបស់ប្រជានេសាទនៅក្នុងសហគមន៍ដ៏ដូចជាមកពីខាងក្រៅសហគមន៍ មិនតែប៉ុណ្ណោះដែននេសាទមានអំណោយផលល្អដល់ការធ្វើចរាចរតាមទូក កាណូត និងធ្វើចរាចររបស់ហ្វូងមច្ឆានៅគ្រប់រដូវ។ ដែននេសាទសហគមន៍មានភ្ជាប់ទៅនឹងដៃអូរ ប្រឡាយ ជាច្រើនដែលទទួលរបបទឹកពីតំបន់ខ្ពង់រាប។ របបទឹកនេះ បានផ្តល់អំណោយផលជាច្រើនដល់ការធ្វើកសិកម្មចិញ្ចឹមសត្វនិងការធ្វើចរាចរពងកូនរបស់ហ្វូងមច្ឆា។ ដែននេសាទសំខាន់ៗ នៅក្នុងកន្លែងនេសាទសហគមន៍ក្របីរៀលមាន ត្រពាំងចំនួន០៨ ព្រៃលិចទឹក វាលស្មៅ និងដីស្រែប្រាំងជាដើម ដែននេសាទទាំងអស់នេះត្រូវបានគ្រប់គ្រងដោយគណៈកម្មការ និងសមាជិកសហគមន៍នេសាទទាំងមូល :

| | | |
|---|---|---|
| - ត្រពាំងច្រកែង | ១១,៤៩៤ ហិកតា | នេសាទចាប់ពី ខែមករា ដល់ខែឧសភា |
| - ត្រពាំងថ្ម | ២,០០៨ ហិកតា | នេសាទចាប់ពី ខែមករា ដល់ខែឧសភា |
| - ត្រពាំងតាពៅ | ០,៦០៣ ហិកតា | នេសាទចាប់ពី ខែកុម្ភៈ ដល់ខែឧសភា |
| - ត្រពាំងកន្លែន | ០,៨០០ ហិកតា | នេសាទចាប់ពី ខែមករា ដល់ខែឧសភា |
| - ត្រពាំងផ្ចោលសេះ | ០,១៧៣ ហិកតា | នេសាទចាប់ពី ខែកុម្ភៈ ដល់ខែឧសភា |
| - ត្រពាំងផ្ចោល | ០,៥៤៥ ហិកតា | នេសាទចាប់ពី ខែតុលា ដល់ខែឧសភា |
| - ត្រពាំងកន្តុត | ០,៦៥៥ ហិកតា | នេសាទចាប់ពី ខែខែកុម្ភៈ ដល់ខែឧសភា |
| - ត្រពាំងចកតូច | ០,២២៥ ហិកតា | នេសាទចាប់ពី ខែខែកុម្ភៈ ដល់ខែឧសភា |
| - ព្រៃលិចទឹក | ១,៤៨៦ ហិកតា | |
| - វាលស្មៅ | ៥១៤ ហិកតា | |
| - ដីកសិកម្ម | ៥៤០ ហិកតា | |

គ-តំបន់មានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

ប្រជាជនប្រមាណ ២០ ភាគរយ នៅក្នុងសហគមន៍នេសាទក្របីរៀលពឹងផ្អែកទាំងស្រុងលើការនេសាទ និងការប្រើប្រាស់ធនធានដែលមាននៅក្នុងសហគមន៍ដើម្បីចិញ្ចឹមជីវិតប្រចាំថ្ងៃ។ ប្រការនេះជាជម្រើសមួយរបស់សហគមន៍

នេសាទក្នុងការគ្រប់គ្រងអភិរក្ស និងប្រើប្រាស់ធនធានក្នុងតំបន់សហគមន៍ឱ្យមាននិរន្តភាពទៅអនាគតដើម្បីរួមចំណែកលើកស្ទួយជីវភាពប្រជាពលរដ្ឋក៏ដូចជាសេដ្ឋកិច្ចជាតិឱ្យរីកចម្រើនឡើង។

ទិសដៅដ៏សំខាន់របស់សហគមន៍ គឺបង្កើតកន្លែងអភិរក្សត្រីមេពូជ និងនាទីព្រៃលិចទឹក ដើម្បីជួយបង្កើនផលស្តុកត្រីធម្មជាតិឱ្យសម្បូរឡើង។ កន្លែងអភិរក្សបានផ្តល់នូវវិសាលភាពដ៏ធំធេងដល់ការរស់នៅ ស្វែងរកចំណី និងកន្លែងពងកូនរបស់មច្ឆាជាតិ ក្រៅពីនេះតំបន់អភិរក្សនៅសហគមន៍នេសាទក្របីរៀលអាចប្រែក្លាយទៅជាតំបន់ទេសចរណ៍ធម្មជាតិ ដែលអាចទាក់ទាញភ្ញៀវទេសចរណ៍មកកំសាន្តបានច្រើនសម្រាប់ចំណូលសហគមន៍។ បន្ទាប់ពីការប្រមូលព័ត៌មាន និងពិគ្រោះយោបល់ជាមួយសមាជិកសហគមន៍រួចមក គណៈកម្មការបានឯកភាពគ្នាជ្រើសរើសយកទីតាំងកន្លែងអភិរក្ស សម្រាប់ធ្វើកន្លែងអភិរក្សត្រីមេពូជ និងព្រៃលិចទឹក ជាតំបន់ទេសចរណ៍ធម្មជាតិមានដូចខាងក្រោម

-ត្រពាំងរាំងជ្រុំ ទំហំ ១ ហិកតា

-ព្រៃលិចទឹក ទំហំ ៩០ ហិកតា

*ឃ-ធនធានជលផល*

តាមការសាកសួរ និងប្រមូលព័ត៌មានពីសំណាក់ចាស់ព្រឹទ្ធាចារ្យ គណៈកម្មការ និងសមាជិកសហគមន៍នេសាទក្របីរៀលបានឲ្យយើងឃើញថា ធនធានជលផលនៅក្នុងសហគមន៍នេសាទនាពេលបច្ចុប្បន្ននេះបើធៀបទៅនឹងទស្សវត្ស៦០នោះ ឃើញថាមានការថយចុះជាលំដាប់ដែលគួរឱ្យព្រួយបារម្ភសម្រាប់អនាគត។ ដោយឡែកបើពិនិត្យជារួមយើងឃើញថា ប្រភេទធនធានជលផលដែលយើងធ្វើការអង្កេតមានដូចខាងក្រោមៈ

**តារាងប្រភេទផលនេសាទ**

| ល.រ | ប្រភេទផលនេសាទ | ល.រ | ប្រភេទផលនេសាទ |
|---|---|---|---|
| ១ | ត្រីរៀល ត្រីលិញ | ២០ | ត្រីចង្វាមូល ត្រីចង្វាស្លឹកឫស្សី ត្រីចង្វាពោត |
| ២ | ត្រីក្រាញ់ | ២១ | ត្រីកំភ្លាញ កំភ្លាញភ្លុក |
| ៣ | ត្រីរ៉ស់ | ២២ | ត្រីឆ្លូញ ត្រីខ្ទឹង |
| ៤ | ត្រីឆ្តោ ដៀម | ២៣ | ត្រីសង្កត់ប្រាក់ ត្រីស្រកាក្តាម |
| ៥ | ត្រីអណ្តែង | ២៤ | ត្រីឆ្លិន ខ្ទងវែង |
| ៦ | ត្រីឆ្លាត | ២៥ | ត្រីប្រម៉ា |
| ៧ | ត្រីកញ្ចុះ កញ្ចុះថ្ម កញ្ចុះក្លោង | ២៦ | ត្រីព្រួល |
| ៨ | ត្រីច្រកែង | ២៧ | ត្រីកំព្រាម |
| ៩ | ត្រីក្អែក | ២៨ | ត្រីតាអោន កំភ្លៀវ |
| ១០ | ត្រីក្រុស | ២៩ | ត្រីឈ្មាត |
| ១១ | ត្រីក្រាយ | ៣០ | ត្រីកញ្ជ្រូក កញ្ជ្រាញប្រាស់ |
| ១២ | ត្រីកាហែ | ៣១ | កន្រ្តងប្រេង អំពិលទុំ |
| ១៣ | ត្រីកន្រ្ទប់ | ៣២ | ត្រីខ្មាន់ បន្ទស់ភ្លុក |
| ១៤ | ត្រីព្រលូង (ជិតផុតពូជ) | ៣៣ | ត្រីក្អិត កំពូលបាយ |
| ១៥ | ត្រីឆ្កោក | ៣៤ | ត្រីកបុកច្រមុះ |
| ១៦ | ត្រីឆ្កោកទីទុយ | ៣៥ | ត្រីកន្រ្ទប់ខ្លា (ជិតផុតពូជ) |
| ១៧ | ត្រីប្រា ប្រាអៀវ ត្រីពោ | ៣៦ | ត្រីក្រសក់ (ជិតផុតពូជ) |
| ១៨ | ត្រីតានេល | ៣៧ | ត្រីថ្ពោង |
| ១៩ | ត្រីសណ្តាយ | ៣៨ | ត្រីដំរី |

## តារាងប្រភេទវារីសត្វ និងបក្សីទឹក

| ល.រ | ប្រភេទវារីសត្វ (សិប្បសត្វ បាណកសត្វ ឧរង្គសត្វ ផលផលិត) | ល.រ | ប្រភេទបក្សីទឹក |
|---|---|---|---|
| ១ | អណ្តើកសកល សណ្តើកស្រែ អណ្តើកបិទមុខ) | ១ | សត្វក្រៀល (ជិតផុតពូជ) |
| ២ | ពស់ព្រលិត ពស់វែក ពស់ថ្លាន់ ពស់ចាន់ល្មម ពស់ត្រីរ៉ស់ ពស់ផ្តក | ២ | សត្វទោម |
| ៣ | ពស់វែកស្រងែ ពស់សម្លាប់កង្កែប ពស់ទឹក ពស់ស្រកាចាស់ | ៣ | សត្វទុង |
| ៤ | ពស់ខ្សែគោ ពស់តុកកែ ពស់ខៀវ | ៤ | សត្វទាព្រៃ (ជិតផុតពូជ) |
| ៥ | អន្ទង់ កង្កែប ហ៊ីង គីង្គក់ ក្អាត | ៥ | សត្វប្រវឹក |
| ៦ | ក្តាម ក្តាមទូក កន្ទេះឡង់ | ៦ | សត្វកុក |
| ៧ | ខ្ចៅ ខ្យង លៀស គ្រុំ | ៧ | សត្វស្មោញ |
| ៨ | កន្ធាយ (ជិតផុតពូជ) | ៨ | សត្វក្រសា (ជិតផុតពូជ) |
| ៩ | ក្រពើ | ៩ | សត្វក្អែកទឹក |
| ១០ | អន្សង | ១០ | សត្វអារអូត |
| ១១ | ភេ (ជិតផុតពូជ) | ១១ | សត្វមាន់ទឹក |
| ១២ | ខ្លាត្រី (ជិតផុតពូជ) | ១២ | សត្វកំពីងដួង (ជិតផុតពូជ) |
| ១៣ | ស្វា | ១៣ | សត្វអាញ៉ាដោ |
| ១៤ | សំពោច (ជិតផុតពូជ) | ១៤ | សត្វក្រដក់ (ជិតផុតពូជ) |
| ១៥ | ស្កា | ១៥ | សត្វនៀលខ្យង (ជិតផុតពូជ) |

## តារាងប្រភេទព្រៃលិចទឹក និងវារីរុក្ខជាតិ

| ល.រ | ប្រភេទរុក្ខជាតិទឹក | ល.រ | ប្រភេទរុក្ខជាតិទឹក |
|---|---|---|---|
| ១ | ដើមរាំង | ១៨ | ដើមញរ៉ៃព្រៃ |
| ២ | ដើមតាអូរ | ១៩ | ដើមបន្លាយួន |
| ៣ | ដើមគ្រោះ | ២០ | ដើមស្លត |
| ៤ | ដើមអញ្ចាញ | ២១ | ដើមស្វាយទឹក |
| ៥ | ដើមថ្វាន់ | ២២ | ដើមកណ្តាប់ចង្អេរ (ជិតផុតពូជ) |
| ៦ | ដើមទៀនព្រៃ | ២៣ | ដើមម្ដេញ |
| ៧ | វល្លិត្រអើក | ២៤ | ដើមបន្លាស្អិត |
| ៨ | ដើមកន្តក់ | ២៥ | ដើមប្រកែង |
| ៩ | ដើមជលា | ២៦ | ដើមសំរក |
| ១០ | ដើមឆ្លឹងពោះ | ២៧ | ដើមស្មោ |
| ១១ | ដើមបន្លាឃ្លេ | ២៨ | កប្លោក |
| ១២ | ដើមខ្នាយមាន់ | ២៩ | ត្រកួន |
| ១៣ | ដើមភ្នំភ្លៀង | ៣០ | ព្រលិត |
| ១៤ | ដើមកន្សែង | ៣១ | ដើមរញៀ |

១៥ ដើមផ្តាំ

១៦ ដើមផ្តោល

១៧ ដើមបបួយ

៣២ ដើមធ្មេញត្រី

៣៣ ដើមភ្នែកព្រាប

៣៤ ដើមទ្រូនំអារអួត

**៤. ការធ្វើនេសាទ**

ការធ្វើនេសាទគឺជាមុខរបរសំខាន់និងជាសកម្មភាពនៃការចិញ្ចឹមជីវិតរបស់សហគមន៍នេសាទ។នៅមុនពេលបង្កើតសហគមន៍នេសាទ ការធ្វើនេសាទតែងតែជួបប្រទះនឹងទំនាស់រវាងអ្នកនេសាទជាលក្ខណៈគ្រួសារ និងអ្នកនេសាទជាលក្ខណៈសិប្បកម្ម ឬនេសាទឧស្សាហកម្ម ដែលជានិច្ចជាកាលមានទំនាស់លើដែនដីធ្វើអាជីវកម្ម និងការប្រើប្រាស់ឧបករណ៍នេសាទធុនធំគ្របដណ្តប់លើឧបករណ៍ធុនតូចៗជាដើម។ ប៉ុន្តែបន្ទាប់ពីការកែទម្រង់វិស័យជលផលរបស់រាជរដ្ឋាភិបាលនាឆ្នាំ២០០០ យើងបានផ្តល់ប្រតិភូកម្មអំណាចដល់ប្រជាពលរដ្ឋក្នុងការរៀបចំសហគមន៍នេសាទ ហើយប្រជាពលរដ្ឋមានដែននេសាទធំទូលាយ និងកាត់បន្ថយទំនាស់ក្នុងដែននេសាទសហគមន៍បានមួយចំណែកធំ។

យោងតាមការសិក្សា និងប្រមូលទិន្នន័យពីមូលដ្ឋាន យើងបានស្ថិតិចំនួនអ្នកនេសាទក្នុងសហគមន៍ អ្នកមិនមែនជាសមាជិក និងអ្នកមកពីខាងក្រៅសហគមន៍រួមទាំងប្រភេទឧបករណ៍នេសាទដូចជាៈ ទូក កាណូត ដែលអាចធ្វើការបែងចែកដូចខាងក្រោមៈ

**ក-អ្នកនេសាទ**

ការប៉ាន់ប្រមាណចំនួនអ្នកនេសាទក្នុងសហគមន៍ តាមតួលេខជាក់ស្តែងបានបង្ហាញឲ្យឃើញថាៈ

-អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន៦.៩៩៦នាក់ ស្ត្រី២២០ នាក់

-អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នៅក្នុងសហគមន៍នេសាទមានចំនួន១.០០៥នាក់ ស្ត្រី១.៧០៤នាក់

-អ្នកនេសាទមិនមែនជាសមាជិកដែលមកពីខាងក្រៅសហគមន៍នេសាទមានចំនួន១៨២នាក់ ស្ត្រី៦២នាក់

**ខ-ឧបករណ៍នេសាទ**

នៅរដូវបើកនេសាទ មានប្រជាពលរដ្ឋនៅក្នុងសហគមន៍ និងមកពីខាងក្រៅសហគមន៍តែងតែមកធ្វើអាជីវកម្មនេសាទដោយប្រើប្រាស់ឧបករណ៍នេសាទដូចជា មងអួសដៃ មងពាក់ និងសំណាញ់ ។ល។

យោងតាមការចុះប្រមូលព័ត៌មានធ្វើការបំផុសគំនិត និងការប៉ាន់ស្មានលើឧបករណ៍នេសាទភាគច្រើនដែលបានប្រើប្រាស់ក្នុងដែននេសាទសហគមន៍បានបង្ហាញឲ្យឃើញថា មានប្រភេទឧបករណ៍ភាគច្រើនដែលបានប្រើប្រាស់ស្របនិងច្បាប់លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ ដែលគណៈកម្មការ និងសមាជិកបានកំណត់រួចហើយ។ តែទោះជាយ៉ាងណាក៏ដោយ ក៏នៅមានឧបករណ៍នេសាទមួយចំនួនតូចដែលនៅប្រព្រឹត្តល្មើសនិងច្បាប់មានដូចជាៈ លបវ៉ាវ ឧបករណ៍ប ឧបករណ៍ឆក់ត្រី អ៊ុយស្បៃមុង។ល។ ដែលទាមទារឲ្យគណៈកម្មការសហគមន៍នេសាទ និងក្រុមល្បាត ធ្វើការអប់រំនិងទប់ស្កាត់បានទាន់ពេលវេលា។ ខាងក្រោមនេះជាប្រភេទឧបករណ៍នេសាទដែលប្រើប្រាស់ក្នុងសហគមន៍នេសាទគ្របីរៀល :

**តារាង ឧបករណ៍នេសាទរបស់សមាជិកសហគមន៍**

| ប្រភេទឧបករណ៍ | ឯកតា | ទំហំប្រវែង(ជាមធ្យម/គ្រួសារ) | ចំនួន(គ្រួសារ) | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|
| សំណាញ់ | ម៉ែត្រ | ៣-៥ | ២២៣ | វស្សា ប្រាំង |
| មងពាក់ | ម៉ែត្រ | ២៥០ | ៣០ | ខែ ០៨-១២ |

| | | | | |
|---|---|---|---|---|
| សន្ទូចរនង | ផ្លែ | ២០០ | ៥០ | ខែ ០៨-០១ |
| លបបង្កប់ | លប | ២០ | ១០ | ខែ ០១-០៥ |
| មងអួស | ម៉ែត្រ | ៥០ | ១០ | ខែ ០១-០៥ |
| ទ្រូកំប៉ោង | គ្រឿង | ២ | ១០០ | ខែ ០១-០៨ |
| អង្រុត | គ្រឿង | ១ | ១០០ | ពេញមួយឆ្នាំ |
| ឈ្នាង | គ្រឿង | ១ | ៥០ | ពេញមួយឆ្នាំ |
| សរុប | | | ៥២៣ | |

**តារាង ទូក កាណូតរបស់សមាជិកសហគមន៍**

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកអុំ | ១០ | ១០០-២០០ | គ្មាន |
| កាណូតធនតូច | ៣០ | ៣០០-៤០០ | ៥-៦ សេះ |

**តារាង ឧបករណ៍នេសាទរបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកសហគមន៍**

| ប្រភេទឧបករណ៍ | ឯកត្តា | ទំហំ ប្រវែង(ជាមធ្យម/គ្រួសារ) | ចំនួន(គ្រួសារ) | រដូវប្រើប្រាស់ឧបករណនេសាទ |
|---|---|---|---|---|
| សំណាញ់ | ម៉ែត្រ | ៦ | ១០០ | ខែ ០៦-០៣ |
| សន្ទូច | ផ្លែ | ២០០ | ៣០ | ខែ ០៨-០១ |
| មងពាក់ | ម៉ែត្រ | ៥០០ | ២០ | ខែ ០៨-១២ |
| ទ្រូកំប៉ោង | ទ្រូ | ២ | ៣០ | ខែ ០៨-០២ |
| អង្រុត | អង្រុត | ២ | ១០០ | ខែ ០៣-០៥ |
| បបក់ | | ១ | ៥០ | ខែ ០៨-០២ |
| សរុប | | | ១៩០ | |

**តារាង តារាងទូក កាណូតរបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកសហគមន៍**

| ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកអុំ | ៣០ | ២០០-៣០០ គ.ក្រ | |
| កាណូតធនតូច | ១០០ | ៣០០-៥០០ គ.ក្រ | ៣.៥ សេះ |
| សរុប | ១៣០ | | |

**តារាង ឧបករណ៍នេសាទរបស់អ្នក មិនមែនជាសមាជិកដែលមកពីខាងក្រៅសហគមន៍នេសាទ**

| ប្រភេទឧបករណ៍ | ឯកត្តា | ទំហំ ប្រវែង (ជាមធ្យម/គ្រួសារ) | ចំនួន (គ្រួសារ) | រដូវប្រើប្រាស់ ឧបករណ៍នេសាទ |
|---|---|---|---|---|
| សំណាញ់ | ម៉ែត្រ | ៣ | ១០០ | វស្សា ត្រាំង |

| | | | | |
|---|---|---|---|---|
| មងអូសដៃ | ម៉ែត្រ | ៥០ | ១០ | ខែ ០៣-០៦ |
| សន្ទូចរនង | ផ្លែ | ៥០០ | ៥០ | ខែ ០៧-១២ |
| តុំ | តុំ | ៥០ | ៥ | ខែ ០៧-១២ |
| លបព្រៀង | លប | ៣០ | ៥ | ខែ ០៦-០៣ |
| ជុច | ជុជ | ២០០ | ១០ | ខែ ០៦-០២ |
| កង្វា | ដើម | ៥ | ៥០ | ខែ ០៣-០៦ |
| លាន់ | គ្រឿង | ៥០ | ២០ | ខែ ០៧-១២ |
| | សរុប | | ២៥០ | |

**តារាង ទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីខាងក្រៅសហគមន៍នេសាទ**

| ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ (គ.ក្រ) | កំលាំងម៉ាស៊ីន(សេះ) |
|---|---|---|---|
| ទូក | ១០ | ១០០-២០០ | |
| កាណូត | ៥០ | ៥០០-៧០០ | ៣៥ |

**គ-ប៉ាន់ប្រម៉ាណផលនេសាទប្រចាំឆ្នាំ**

ជាមធ្យមការធ្វើអាជីវកម្មនេសាទជាលក្ខណៈគ្រួសាររបស់សមាជិកសហគមន៍នេសាទនៅរដូវបើក និងបិទ ដោយប្រើឧបករណ៍មងរាយ មងអូស សន្ទូចរនង សំណាញ់.....។ល។

| ប្រភេទផលនេសាទទៅតាមប្រភេទឧបករណ៍ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ(គិតជា គ.ក្រ) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីគ្រប់ប្រភេទ | ៥៤០ គ.ក្រ | ៣០០ គ.ក្រ | ៨៤០ គ.ក្រ |
| អន្ទង់ | ៥០ គ.ក្រ | ១០០ គ.ក្រ | ១៥០ គ.ក្រ |
| កង្កែប | | ២០០ គ.ក្រ | ២០០ គ.ក្រ |
| កំពិស | | ៤០០ គ.ក្រ | ៤០០ គ.ក្រ |
| ក្តាម ខ្យង | ១០០គ.ក្រ | ១៥០គ.ក្រ | ២៥០ គ.ក្រ |
| សរុប | | | ១.៨៤០ |

## ៥. ផែនការគ្រប់គ្រងតំបន់នេសាទសហគមន៍

**ក-ទស្សនៈវិស័យ**

ប្រជាពលរដ្ឋនៅក្នុងសហគមន៍មានចំណេះដឹងខ្ពស់ក្នុងការគ្រប់គ្រងសហគមន៍នេសាទ និងមានជីវភាពធូរធារ តាមរយៈការចូលរួមអភិរក្សនិងប្រើប្រាស់ធនធានធម្មជាតិក្នុងសហគមន៍ប្រកបដោយសមធម៌ និងចីរភាពដែលជាចំណែកមួយជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋក្នុងសហគមន៍។

**ខ-គោលបំណង**

-ចូលរួមគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋប្រកបដោយសមធម៌។

-ធ្វើឲ្យប្រសើរឡើងនូវជីវភាពសហគមន៍នេសាទ តាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម។

-ដើម្បីឲ្យប្រជាពលរដ្ឋខ្មែរយល់ច្បាស់អំពីច្បាប់ និងលក្ខន្តិកៈរបស់សហគមន៍ ហើយចូលរួមធ្វើជាម្ចាស់លើ ធនធានធម្មជាតិក្នុងសហគមន៍។

-ផ្តល់ប្រតិភូកម្មអំណាចដល់ប្រជានេសាទក្នុងការចូលរួមគ្រប់គ្រងនិងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តភាព ជាពិសេសការគ្រប់គ្រងផ្ទៃដីដែលបានកាត់បន្ថយពីនាទីឡូត៍នេសាទ សម្រាប់ការធ្វើអាជីវកម្មនេសាទឲ្យបានសមស្របនិងយូរអង្វែង។

### គ-ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

#### គ.១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំដោយគិតគូរនិងវាយតម្លៃអំពីទំហំដែននេសាទ ចំនួនឧបករណ៍នេសាទ ប្រភេទឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងការប៉ាន់ប្រមាណផលស្តុកដែលមាននៅក្នុងដែននេសាទដោយធ្វើយ៉ាងណាមិនឲ្យមានការនេសាទលើសពីធនធានដែលមាននៅក្នុងសហគមន៍ ។

ឆ្លងតាមការសិក្សា និងវាយតម្លៃលើកត្តាដូចខាងលើ គណៈកម្មការបានរៀបចំផែនការប្រើប្រាស់ ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍មានដូចខាងក្រោម :

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទឧបករណ៍ | ទំហំ/ប្រវែង | ចំនួន (គ្រួសារ) | |
| ត្រពាំងតាពៅ ត្រពាំងផ្ទោលសេះ ត្រពាំងកន្តុត ត្រពាំងថ្ម ត្រពាំងប្រកែង ត្រពាំងផ្ទោល | ខែ០១ ដល់ខែ០៤ | មងពាក់ | ៥០០ ម៉ែត្រ | ៨១ | (១,៥សម) |
| | ខែ០២ ដល់ខែ០៥ | មងអូសដៃ | ៥០ ម៉ែត្រ | ១៣ | (១,៥សម) |
| | ខែ០១ ដល់ខែ០៣ | អួញ្ជង | ៥ ម៉ែត្រ | ០៥ | (១,៥សម) |
| | ខែ០១ ដល់ខែ១២ | សំណាញ់ | ៣ ម៉ែត្រ | ២១៥ | (១,៥សម) |
| | ខែ០៦ ដល់ខែ១២ | លាន់ | ៥០ លាន់ | ៥០ | បំពង់ឫស្សី |
| | ខែ០៧ ដល់ខែ០៣ | ឡើ | ២៥ ឡើ | ២០ | (០,៥សម) |
| | ខែ០១ ដល់ខែ១២ | លបកំភ្លាញ | ២០ លប | ៥ | (១,៥សម) |
| | ខែ០៥ ដល់ខែ០៩ | លបព្រៀង | ១០ គូ | ៣០ | (១,៥សម) |
| | ខែ០៦ ដល់ខែ១០ | សាងគ្មានកៃវត្តៈ | ១ | ២០ | ផ្លែ៥ |
| | ខែ០១ ដល់ខែ០៧ | លបបង្កប់ | ៥០ លប | ១០ | (១,៥សម) |
| | ខែ០៦ ដល់ខែ១២ | សន្ទូចរនង | ៥០០ ផ្លែ | ១០០ | ផ្លែ១ |
| | | សរុប | | ៥៤៩ | |

### គ.២-ផែនការកែលម្អដែននេសាទ

ដោយផ្អែកលើការប្រជុំពិភាក្សារវាងអ្នកសម្របសម្រួល គណៈកម្មការ និងសមាជិកសហគមន៍នេសាទយើងពិនិត្យឃើញថា នៅក្នុងសហគមន៍នេសាទក្របីរៀល មានសកម្មភាពល្មើសច្បាប់ជាច្រើនដូចជា ការកាប់ព្រៃលិចទឹក ផក់ត្រី មងក្រឡាញឹក ។ល។ ហេតុនេះភារកិច្ចជាចំបងទាមទារការការពារយាមល្បាត និងការចូលរួមការគាំទ្រពីសំណាក់សមាជិកសហគមន៍ អាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធនានា។ សកម្មភាពផែនការកែលម្អដែននេសាទបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម:

| ឈ្មោះដែននេសាទ | ទំហំ | ទំហំដែលត្រូវកែលម្អ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | តម្លៃ ប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| សហគមន៍នេសាទក្របីរៀល | ១ម x0,៥ម | ជុំវិញព្រំប្រទល់កន្លែងសហគមន៍នេសាទ | បោះស្លាកសញ្ញាចំនួន ១០ស្លាក | ខែ៦ ២០១៩ | ខែ៦ ២០២២ | ៤.០០០.០០០ រៀល |
| គ្រពាំងរាំងជ្រុំ | ០,៥ហ.ត | ស្តារត្រពាំង | អេស្កាវ៉ាទ័រ | ខែ៦ ២០១៩ | ខែ៦ ២០២២ | ២០.០០០.០០០ រៀល |

### គ.៣-ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ការកំណត់រៀបចំកន្លែងអភិរក្សនេះ គឺដើម្បីធានាបាននូវប្រសិទ្ធិភាពនៃការប្រើប្រាស់ធនធានជលផលប្រកបដោយចីរភាព។ ឆ្លងតាមការចុះអង្កេតពិនិត្យវិនិច្ឆ័យតាមលក្ខណៈបច្ចេកទេសនោះឃើញថា តំបន់បឹងរាំងជ្រុំគឺជាតំបន់ដែលគ្របដណ្តប់ដោយព្រៃលិចទឹកព័ទ្ធជុំវិញហើយត្រូវបានគណៈកម្មការសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធបានមូលមតិគ្នារួមសហការគ្នាបង្កើតដែនអភិរក្សត្រីមេពូជ និងពពួកសត្វស្លាប។

តាមសកម្មភាពជាក់ស្តែងនៅក្នុងសហគមន៍បានបញ្ជាក់ឲ្យឃើញថា គណៈកម្មការ និងសមាជិកសហគមន៍មានឆន្ទៈចូលរួមក្នុងការគ្រប់គ្រងការពារធនធាននៅក្នុងដែនអភិរក្ស ដើម្បីជាប្រយោជន៍ ក្នុងការធានានិរន្តរភាព និងតម្រូវការជលត្រីរបស់ប្រជាពលរដ្ឋក្នុងសហគមន៍។ ការបង្កើតតំបន់អភិរក្សត្រីមេពូជ ជាចាំបាច់ត្រូវធ្វើការរៀបចំកំណត់ព្រំប្រទល់ ស្លាកសញ្ញា ក្តាពត៌មានបិទផ្សាយបទបញ្ញាតិសម្រាប់កន្លែងអភិរក្ស សាងសង់រោងយាមសម្រាប់ក្រុមល្បាតបំពេញការងារនិងសម្ភារៈល្បាតមួយចំនួនទៀត។

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម:

| ឈ្មោះ និងទីតាំង | ទំហំ | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| បឹងរាំងជ្រុំ | ១,៧ហិកតា | ដែនអភិរក្សត្រីមេពូជ | -ការពារដែនអភិរក្ស<br>-ដាក់ស្លាកសញ្ញា | ខែ៦ ២០១៩ | ខែ៦ ២០២២ | ២០.០០០.០០០ រៀល |

| | | | | | | |
|---|---|---|---|---|---|---|
| | | | -ដាក់ជម្រកសិប្ប និមិត្ត | | | |
| ព្រៃលិចទឹក | ២ហិកតា | អភិរក្សព្រៃ | -ដាក់ស្លាកសញ្ញា<br>-ការពារនិងអភិរក្ស | ខែ៦ ២០១៩ | ខែ៦ ២០២២ | ៤.០០០.០០០ រៀល |

**គ.៤-ផែនការគ្រប់គ្រងព្រៃលិចទឹក**

នាទីព្រៃលិចទឹកមានគ្រប់លើតំបន់សហគមន៍នេសាទមួយភាគធំ ព្រៃបានផ្តល់នូវសក្តានុពលភាព និងសារៈសំខាន់ជាច្រើនដល់ត្រី និងពពួកវារីសត្វមានមានជីវិតគ្រប់ប្រភេទសម្រាប់ជាជម្រករស់នៅ បង្កបង្កើតកូន និងផ្តល់ជាចំណីផងដែរ។ មិនតែប៉ុណ្ណោះនាទីព្រៃលិចទឹកបានជួយរក្សាលំនឹងបរិស្ថានធម្មជាតិទប់ស្កាត់ការហូរច្រោះ ទឹករលក ជារបាំងខ្យល់ជាដើម ជាពិសេសជួយបង្កើនផលត្រី និងពពួកសត្វមានជីវិតគ្រប់ប្រភេទឲ្យសម្បូរឡើង។

ចំពោះដែនគ្រប់គ្រងព្រៃលិចទឹក គណៈកម្មការបានបែងចែកកំណត់ក្នុងផែនទីធនធានសហគមន៍ ជាតំបន់អភិរក្ស និងតំបន់ប្រើប្រាស់វល្លិ។ តំបន់ប្រើប្រាស់គឺធ្វើយ៉ាងណាអប់រំណែនាំដល់ប្រជាពលរដ្ឋឲ្យចេះកាប់វល្លិមែក។ (ដោយធ្វើយ៉ាងណាមិនឲ្យងាប់ដើម) ដើម្បីយកមកប្រើប្រាស់ជាអុសចំអិនអាហារ។ ការកាប់វល្លិនេះគឺជាលក្ខណៈវិលជុំវៀងរាល់បីឆ្នាំម្តង ដើម្បីឲ្យព្រៃមានលទ្ធភាពអាចដុះលូតលាស់ឡើងវិញបាន។

ដោយមានការយល់ដឹងពីសារៈសំខាន់នៃព្រៃលិចទឹកប្រជានេសាទមានការចូលរួមចំណែកយ៉ាងសកម្មក្នុងការគ្រប់គ្រងធនធានក្នុងតំបន់ឲ្យប្រសើរឡើង។

ខាងក្រោមនេះជាផែនការគ្រប់គ្រងនាទីព្រៃលិចទឹកក្នុងសហគមន៍ ដែលគណៈកម្មការ និងសមាជិកបានរៀបចំលើកឡើង:

| ឈ្មោះនិងទីតាំង | ទំហំ | ប្រភេទកូនឈើដែលត្រូវដាំនិងការពារ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ព្រៃលិចទឹកស្ពោអណ្តូង | ៧ហិកតា | ដើមរាំង. ផ្តោល.ច្រកែង . តាអូរ | -អប់រំផ្សព្វផ្សាយ<br>-ថែរក្សាការពារព្រៃលិចទឹក<br>-ថែរក្សាកូនឈើដែលទើបដុះ | ខែ៦ ឆ្នាំ ២០១៩ | ខែ៥ ឆ្នាំ ២០២០ | ១២.០០០.០០០រ |

**គ.៥-ផែនការអភិវឌ្ឍវារីវប្បកម្ម**

ក្រៅពីការនេសាទត្រី នៅមានការចិញ្ចឹមត្រីតាមស្រះ ជាមុខរបរមួយបន្ថែមក្នុងគ្រួសាររបស់ប្រជានេសាទនៅក្នុងសហគមន៍នេសាទក្របីរៀល។

ការចិញ្ចឹមត្រីតាមស្រះ ជាទិសដៅដ៏សំខាន់របស់វិស័យជលផលក្នុងការបង្កើនមុខរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ និងដើម្បីកាត់បន្ថយការប្រើប្រាស់ធនធានធម្មជាតិក្នុងសហគមន៍នេសាទ។

ដោយយោងតាមការវិវត្តន៍ទៅរកភាពរីកចម្រើននាសម័យបច្ចុប្បន្ននេះ និងការកើនឡើងនូវចំនួនអ្នកនេសាទ ប្រភេទឧបករណ៍នេសាទមួយចំនួនកាន់តែទំនើបក្នុងការចាប់ ឬប្រមូលធនធានជលផល ហើយមួយចំណែកទៀតមានការនេសាទហួសកំរិត។ ដូចច្នេះហើយទើបទាមទារឲ្យគណៈកម្មការ សមាជិកសហគមន៍និងអ្នកពាក់ព័ន្ធនានាត្រូវសិក្សាស្វែងយល់ក្នុងការដោះស្រាយ ជីវភាពរបស់សមាជិកក្នុងសហគមន៍នេសាទក៏ដូចជាជួយបង្កើតមុខរបរចិញ្ចឹមជីវិតបន្ទាប់បន្សំ ដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយការនេសាទហួសកំរិត និងជួយលើកកម្ពស់ស្បៀងអាហារប្រចាំគ្រួសារទផងដែរ។

ឆ្លើយតបនិងការបង្កើតមុខរបរបន្ថែមដល់សមាជិកសហគមន៍ គណៈកម្មការសហគមន៍នេសាទបានរៀបចំផែនការបានរៀបចំឡើងដូចខាងក្រោមៈ

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| ចិញ្ចឹមតាមស្រះ | ២០គ្រួសារ | -ទីឡាព្យា<br>-ឆ្ពិន<br>-កាបសមញ្ញ<br>-កាបស<br>-កាបឥណ្ឌា | ៤០០ក្បាល/គ្រួសារ | ចាប់ផ្តើម ខែ៦ ឆ្នាំ ២០១៩ | ប្រមូល ខែ ៦ ឆ្នាំ ២០២២ |

### គ.៦-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ចំពោះថវិកាសម្រាប់ទ្រទ្រង់ និងអភិវឌ្ឍន៍សហគមន៍នេសាទ គណៈកម្មការមានតួនាទីសំខាន់ក្នុងការស្វែងរកប្រាក់ចំណូល និងចំណាយដោយស្របច្បាប់ពីគ្រប់រូបភាពតាមរយៈស្នើរសុំពីអង្គការក្នុង ឬក្រៅរដ្ឋាភិបាលនានាដើម្បីធានាដល់ជីវភាពរបស់សមាជិកសហគមន៍នេសាទគ្រប់រូប។

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃ ខែ ឆ្នាំចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំបញ្ចប់ | ចំណូលសរុប | ប្រភពទុន |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ភាគទានប្រចាំឆ្នាំពីសមាជិកសហគមន៍ | ខែ៧ ឆ្នាំ ២០១៩ | ខែ៧ ឆ្នាំ ២០២១ | ២.០០០.០០០៛ | សមាជិកសហគមន៍ |
| ពីអ្នកខាងក្រៅឬអ្នកមិនមែនជាសមាជិកសហគមន៍ | ពីអ្នកខាងក្រៅឬអ្នកមិនមែនជាសមាជិកសហគមន៍ | ខែ៧ ឆ្នាំ ២០១៩ | ខែ៧ ឆ្នាំ ២០២១ | ៣.០០០.០០០៛ | ប្រជានេសាទ |

### គ.៧. ផែនការផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ

ពេលបច្ចុប្បន្ន ធនធានជលផលក្នុងសហគមន៍កំពុងទទួលរងនូវការគំរាមកំហែងពីអ្នកខាងក្នុងនិងខាងក្រៅដោយការកាប់រានព្រៃលិចទឹក និងការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់។ដូចនេះដើម្បីធានាការប្រើប្រាស់ធនធានជលផលពេលអនាគតនិងបានយូរអង្វែងនោះ តម្រូវធ្វើការផ្សព្វផ្សាយអំពីច្បាប់ស្តីពីជលផល និងលិខិត

បទដ្ឋានពាក់ព័ន្ធឲ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន ដើម្បីឲ្យមានការយល់ដឹងគ្រប់គ្រាន់ និងចូលរួមចំណែកក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តភាព។ ការផ្សព្វផ្សាយអំពីច្បាប់ស្តីពី ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធក្នុងគោលបំណង៖

- បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋក្នុងសហគមន៍
- កាត់បន្ថយសកម្មភាពបទល្មើសនេសាទក្នុងសហគមន៍ផែនការសកម្មភាពមានដូចខាងក្រោម៖

| ឈ្មោះសកម្មភាព | អ្នកទទួលខុសត្រូវ | រយៈពេលអនុវត្ត | | | តម្លៃប៉ាន់ស្មាន (គិតដុល្លា) | ប្រភពទុន |
|---|---|---|---|---|---|---|
| | | ២០១៩ | ២០២០ | ២០២១ | | |
| ផ្សព្វផ្សាយពីច្បាប់ជលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធ | ខណ្ឌរដ្ឋបាលជលផល គណៈកម្មការ | ២ | ២ | ២ | ៦០០$ | ខណ្ឌរដ្ឋបាលជលផល ចរិកាឃុំ និងដៃគូអភិវឌ្ឍន៍ |
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជា | គណៈកម្មការ | ៣ | ៣ | ៣ | ៩០០$ | ចរិកាឃុំ និងដៃគូអភិវឌ្ឍន៍ |
| | | | | | សរុប= ១៥០០$ | |

ឃ-យុទ្ធសាស្ត្រ

ឆ្លើយតបនិងការអនុវត្តផែនការឲ្យទទួលបានជោគជ័យជាផ្លែផ្កាក្នុងរយៈពេល០៣ឆ្នាំដែលបានរៀបចំមកនេះ តាមនាមសហគមន៍នេសាទក្របីរៀលមានយុទ្ធសាស្ត្រមួយចំនួនដូចខាងក្រោមៈ

-បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ផែនការរួមមានៈ សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ព្រឹទ្ធាចារ្យ និងសមាជិកសហគមន៍នេសាទដែលមានបទពិសោធន៍ និងចំណេះ ដឹងល្អក្នុងការដឹកនាំ និងគ្រប់គ្រងការងារ។

-ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ចដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាទាក់ទងនិងបច្ចេកទេសជលផលដូចជាៈការធ្វើផែនការកន្លែងអភិរក្សមេពូជត្រីការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកចរិកាទ្រទ្រង់ជាដើម។

-សុំជំនួយបច្ចេកទេសពីសមត្ថកិច្ចជំនាញ និងស្ថាប័នពាក់ព័ន្ធ ដើម្បីជួយផ្តល់យោបល់ចំពោះផែនការដែលទាក់ទងនឹងបច្ចេកទេស ដូចជាការធ្វើផែនការអភិរក្សត្រីមេពូជ ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី។

-ទំនាក់ទំនងជាមួយស្ថាប័នជំនាញ និងស្ថាប័នជំនាញនានា គម្រោង ម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រថវិកាសម្រាប់ដំណើរការអនុវត្តផែនការ។

-រៀបចំកម្មវិធីអនុវត្តន៍ផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់ ។

-ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធ សំខាន់ៗដើម្បីជំរុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងបានប្រសិទ្ធិភាពល្អ។

-កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ។

-រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍។

-សហការដើម្បីចាត់វិធានការយ៉ាងតឹងរឹង ចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍។

-ពង្រឹងសមត្ថភាពបច្ចេកទេសនិងបទពិសោធន៍ក្នុងការអភិវឌ្ឍន៍សហគមន៍នេសាទ។

-ចងក្រងក្រុមនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ។
-បញ្ចូលផែនការការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ។

**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រពាំងរៀល រយៈពេល ៣ ឆ្នាំ (២០១៩-២០២១)**

| ប្រភេទផែនការ/សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មាន(ដុល្លា) | ប្រភពជំនួយ | ពេលផ្ដើម | ពេលបញ្ចប់ |
|---|---|---|---|---|---|
| ១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ | • កាត់បន្ថយទំនាស់នេសាទក្នុងកន្លែងនេសាទ<br>• កាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់<br>• សហគមន៍នឹងអនុវត្តន៍ប្រកាសស្ដីពីការប្រើប្រាស់ឧបករណ៍ | ៦០០$ | រាជរដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | | |
| ១.១.ប្រជុំផ្សព្វផ្សាយការប្រើប្រាស់ឧបករណ៍នេសាទលក្ខណៈគ្រួសារក្នុង១ឆ្នាំ/២ដង | សមាជិកសហគមន៍នឹងយល់ដឹងពីការការប្រើប្រាស់ឧបករណ៍នេសាទលក្ខណៈគ្រួសារ | ៤០០$ | ស្វែងរកថវិការ | ០៦/២០១៩<br>១ឆ្នាំ២ដងនៅ | ០៦/២០២១<br>រដូវបិទនេសាទ |
| ១.២.ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ | អ្នកពាក់ព័ន្ធ នឹងចូលរួមផ្សព្វផ្សាយបន្តដល់សហគមន៍ដ៏ទៃ | ២០០$ | | | |
| **២.ផែនការកែលម្អរដែននេសាទ** | បង្កើនផលត្រី វារីសត្វគ្រប់ប្រភេទ និងព្រៃលិចទឹកជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ ។ | **៥.២០០$** | | | |
| ២.១.បោះស្លាកសញ្ញាចំនួន១០ និងស្ដាត្រពាំងរាំងជ្រំ ទំហំ ០.៥ហិកតា | -ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធទាំងអស់<br>-ធ្វើការសិក្សាលើទំហំដែលត្រូវនិងស្ដារបឹងអាចស្តុកទឹកបានពេញមួយឆ្នាំ | ៦.០០០$ | រាជរដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ១០/២០១៩ | ០៥/២០២១ |
| ៣.ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស | • ប្រភេទត្រីមេពូជ សត្វវារីសំខាន់ៗ ត្រូវបានធ្វើការអភិរក្ស<br>• ប្រភេទព្រៃលិចទឹកនឹងត្រូវបានការពារ<br>• ប្រជាជនបានយល់ដឹងពីសារៈប្រយោជន៍កន្លែងអភិរក្ស | ៦.០០០$ | រាជរដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ១០/២០១៩ | ០៥/២០២១ |
| ៣.១ អភិរក្សជម្រកត្រីមេពូជ | • បង្គោលនឹងបានបោះនៅកន្លែងអភិរក្ស | | រាជរដ្ឋាភិបាល | ១០/២០១៩ | |

| | | | | | |
|---|---|---|---|---|---|
| | • ប្រជាជនបានស្គាល់និងមានការយល់ដឹងពីសារៈប្រយោជន៍កន្លែងអភិរក្សជម្រកត្រីមេពូជ | ៦.០០០$ | អង្គការដៃគូ<br>សប្បុរសជន | | ០៥/២០២១ |
| ៣.២.ចុះល្បាតជាប្រចាំ | បទល្មើសនេសាទនិងមានការថយចុះតាមរយៈការចុះល្បាត | | | | |
| **៤.ការគ្រប់គ្រងព្រៃលិចទឹកសហគមន៍នេសាទ** | • សមាជិកសហគមន៍យល់ដឹងពីសារៈសំខាន់នៃព្រៃលិចទឹក<br>• ព្រៃលិចត្រូវបានការពារដោយសមាជិកសហគមន៍នេសាទ | ៣.០០០$ | រាជរដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ១០/២០១៩ | ០៥/២០២១ |
| ៤.១.ថែរក្សានិងការពារព្រៃលិចទឹកទំហំ១៦២ហិចតា | • ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធទាំងអស់<br>• ដាក់ស្លាកសញ្ញាការពារ<br>• តាមដាន ត្រួតពិនិត្យ និងការពារ | ១.២០០$<br>១.៨០០$ | សហគមន៍<br>រាជរដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ០១/២០១៩<br>០៩/២០១៨<br>១២/២០១៨ | ០១/២០១៩<br>១២/២០១៩<br>១២/២០២១ |
| ៤.២.ប្រជុំផ្សព្វផ្សាយពីសារៈប្រយោជន៍ព្រៃលិចទឹកដល់សមាជិកសហគមន៍នេសាទ | • សមាជិកចំនួន ៨៥នាក់ស្រី៥៥ នាក់ចូលរួមប្រជុំផ្សព្វផ្សាយ<br>• សមាជិកសហគមន៍យល់ដឹងកាន់តែច្បាស់ពីសារៈប្រយោន៍និងចូលរួមក្នុងការការពារថែរក្សាព្រៃលិចទឹក | | | | |
| ៤.៣.ចុះល្បាតជាប្រចាំ | គណៈកម្មការ និងសមាជិកចូលរួមទប់ស្កាត់ការកាប់បំផ្លាញព្រៃលិចទឹក | | | | |
| **៥.ការអភិវឌ្ឍន៍វារីវប្បកម្ម** | • បង្កើនត្រីសាច់សម្រាប់ហូបចុកក្នុងមូលដ្ឋាន<br>• រកប្រាក់ចំណូលជួយស្ដួយសេដ្ឋកិច្ចគ្រួសារ<br>• កាត់បន្ថយសម្ពាធនេសាទលើធនធានជលផលហូសកំរិត។ | ៤៥០ដុល្លា | | | |
| **៥.១.ការចិញ្ចឹមត្រីស្រះ ចំនួន២០គ្រួសារ ជាលក្ខណៈគ្រួសារ** | | ២០០$ | សហគមន៍<br>រាជរដ្ឋាភិបា | ០១/២០១៩ | ១២/២០២១ |
| ៥.១.១.ជ្រើសរើសសមាជិកសហគមន៍ | ចំនួន២០គ្រួសារ សមាជិកសហគមន៍ស្ម័គ្រចិត្ត | | | | |

| | | | | | |
|---|---|---|---|---|---|
| ៥.១.២.បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី | ២០គ្រួសារ នឹងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម | | ល អង្គការដៃគូសប្បុរសជន | | |
| ៥.១.៥ ត្រួតពិនិត្យតាមដាន | ចំនួន២០ គ្រួសារ នឹងធ្វើការពិនិត្យជាប្រចាំក្នុងពេលចិញ្ចឹមត្រី | | | | |
| ៦.ផែនការថវិកាសម្រាប់ទ្រទ្រង់សហគមន៍នេសាទ | | ៣៥០$ | | | |
| ៦.១ ភាគទានពីអ្នកខាងក្រៅឬអ្នកមិនមែនជាសមាជិកសហគមន៍នេសាទ | ទទួលប្រាក់ភាគទានពីអ្នកខាងក្រៅឬអ្នកមិនមែនជាសមាជិក | ៥០០$ | អ្នកខាងក្រៅ | ០១/២០១៩ | ១២/២០២១ |
| ៦.២.ភាគទានប្រចាំឆ្នាំ | ប្រមូលប្រាក់ពីសមាជិកសហគមន៍នេសាទ | ៧៥០$ | សមាជិក | ០១/២០១៩ | ១២/២០២១ |
| ៦.៣ ភាគទានផ្សេងៗ | ទទួលប្រាក់ភាគទានពីអ្នកខាងក្រៅ អង្គការដៃគូសប្បុរសជន | ៥០០$ | សប្បុរសជន | | |
| ៧.ផ្សព្វផ្សាយពីច្បាប់ជលផលនិងលិខិតបទដ្ឋាន និងកសាងសមត្ថភាពគណៈកម្មការសហគមន៍ | • បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋ<br>• កាត់បន្ថយសកម្មភាពបទល្មើសនេសាទ<br>• គណៈកម្មការនឹងកសាងសមត្ថភាពក្នុងគ្រប់គ្រងសហគមន៍ | ១.៥០០$ | រាជរដ្ឋាភិបាល អង្គការដៃគូសប្បុរសជន | ០១/២០១៩ | ១២/២០២១ |
| ៧.១.ផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ | | | | | |
| ៧.១.១.ផ្សព្វផ្សាយពីច្បាប់ជលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធ | ច្បាប់ជលផល និងលិខិតបទដ្ឋាន នឹងត្រូវបានផ្សព្វផ្សាយ<br>• សមាជិកសហគមន៍នេសាទ | ៦០០$ | | ០១/២០១៩ | ១២/២០២១ |
| ៧.១.២.ផ្សព្វផ្សាយលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង | • លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងនឹងត្រូវបានផ្សព្វផ្សាយសមាជិកសហគមន៍នេសាទ | ៩០០$ | | ០១/២០១៩ | ១២/២០២១ |

# តារាងកម្មវិធីការងារប្រចាំឆ្នាំ ២០១៩-២០២១

| ប្រភេទផែនការសកម្មភាព | កាលបរិច្ឆេទ ២០១៩ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| ១.ការប្រើប្រាស់ឧបណ៍នេសាទ | | | | | | | | | | | | |
| ១.១.ប្រជុំផ្សព្វផ្សាយបទបញ្ញាផ្ទៃក្នុង | | | x | | | | | | | | | x |
| ១.២.ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ | | | | | | | x | | | | | |
| ១.៣.ត្រួតពិនិត្យ និងតាមដាន | | | x | x | x | x | x | x | x | x | x | x |
| ២.ការកែលំអផែននេសាទ | | | | | | | | | | | | |
| ២.១.បាររពើក ស្មៅ និងជីកការស្តារបឹង | | | | | | | | | | | | |
| ៣.ការរៀបចំកន្លែងអភិរក្ស | | | | | | | | | | | | |
| ៣.១.អភិរក្សជម្រកត្រីមេពូជ | | | | | | | | | | | | |
| ៣.២ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋពីកន្លែងអភិរក្ស | | | | | | | | | | | | |
| ៣.៣.ផលិតផ្ទាំងប៉ាណូផ្សព្វផ្សាយ | | | | | | | | | | | | |
| ៣.៤.ចុះល្បាតជាប្រចាំ | x | x | x | x | x | x | x | x | x | x | x | x |
| ៤.ការគ្រប់គ្រងព្រៃលិចទឹកសហគមន៍នេសាទ | | | | | | | | | | | | |

| ប្រភេទផែនការសកម្មភាព | កាលបរិច្ឆេទ ២០២០ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| ១.ការប្រើប្រាស់ឧបណ៍នេសាទ | | | | | | | | | | | | |
| ១.១.ប្រជុំផ្សព្វផ្សាយបទបញ្ញាផ្ទៃក្នុង | | | x | | | x | | | x | | | x |
| ១.២.ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ | | | | | | | x | | | | | |
| ១.៣.ត្រួតពិនិត្យ និងតាមដាន | x | x | x | x | x | x | x | x | x | x | x | x |
| ២.ការកែលំអផែននេសាទ | | | | | | | | | | | | |
| ២.១.បាររពើក ស្មៅ និងជីកការស្តារបឹង | | | | | | | | | | x | x | x |
| ៣.ការរៀបចំកន្លែងអភិរក្ស | | | | | | | | | | | | |
| ៣.១.អភិរក្សជម្រកត្រីមេពូជ | | | | | | | | | | | | |
| ៣.២ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋពីកន្លែងអភិរក្ស | | | | | | | | | | | | |
| ៣.៣.ផលិតផ្ទាំងប៉ាណូផ្សព្វផ្សាយ | | | | | | | | x | x | x | x | x |
| ៣.៤.ចុះល្បាតជាប្រចាំ | x | x | x | x | x | x | x | x | x | x | x | x |
| ៤.ការគ្រប់គ្រងព្រៃលិចទឹកសហគមន៍នេសាទ | | | | | | | | | | | | |

| ប្រភេទផែនការសកម្មភាព | កាលបរិច្ឆេទ ២០២១ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| ១.ការប្រើប្រាស់ឧបណ៍នេសាទ | | | | | | | | | | | | |
| ១.១.ប្រជុំផ្សព្វផ្សាយបទបញ្ញាផ្ទៃក្នុង | | | x | | | x | | | x | | | x |
| ១.២.ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ | | | | | | | x | | | | | |
| ១.៣.ត្រួតពិនិត្យ និងតាមដាន | x | x | x | x | x | x | x | x | x | x | x | x |
| ២.ការកែលំអផែននេសាទ | | | | | | | | | | | | |
| ២.១.បាររពើក ស្មៅ និងជីកការស្តារបឹង | x | x | x | x | x | x | x | x | x | x | x | x |
| ៣.ការរៀបចំកន្លែងអភិរក្ស | | | | | | | | | | | | |
| ៣.១.អភិរក្សជម្រកត្រីមេពូជ | | | x | x | x | x | x | x | x | x | x | x |
| ៣.២ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋពីកន្លែងអភិរក្ស | x | x | | | | | | | | | | |
| ៣.៣.ផលិតផ្ទាំងប៉ាណូផ្សព្វផ្សាយ | x | x | x | x | x | | | | | | | |
| ៣.៤.ចុះល្បាតជាប្រចាំ | x | x | x | x | x | x | x | x | x | x | x | x |
| ៤.ការគ្រប់គ្រងព្រៃលិចទឹកសហគមន៍នេសាទ | | | | | | | | | | | | |

| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៤.១.ប្រជុំផ្សព្វផ្សាយពីសារៈប្រយោជន៍ព្រៃលិចទឹកដល់សមាជិកសហគមន៍នេសាទ | | | | | | x | | | | | | x | | | | | | x | | | | | | x | | | | | | x | | | | | | x |
| ៤.២.ដាំព្រៃលិចទឹកនៅ | | | | | | | | | | | | | | | | | | | | | | | | | | | | | x | x | x | x | x | | | |
| ៤.៣.ថែរក្សានិងការពារព្រៃលិច | | | | | | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ៤.៣ ចុះល្បាតជាប្រចាំ | | | | | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| **៥.ការអភិវឌ្ឍន៍វារីវប្បកម្ម** | | | | | x | | | | | | x | | | | | | x | | | | | | x | | | | | | x | | | | | | x | |
| ៥.១.ការចិញ្ចឹមត្រីតាមស្រះ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៥.១.១.ជ្រើសរើសសមាជិកសហគមន៍ស្ម័គ្រចិត្ត | | | | | | | | x | x | x | | | | | | | | | | | | | | | | | | | | | | | | | | |
| ៥.១.២.បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី | | | | | | | | x | x | x | | | | | | | | | | | | | | | | | | | | | | | | | | |
| ៥.១.៣.ធ្វើបែចិញ្ចឹមត្រី | | | | | | | | x | x | x | | | | | | | | | | | | | | | | | | | | | | | | | | |
| ៥.១.៤.ការដាក់កូនត្រីដាក់ក្នុងស្រះ | | | | | | | | x | x | x | | | | | | | | | | | | | | | | | | | | | | | | | | |
| ៥.១.៥ ត្រួតពិនិត្យតាមដាន | | | | | | | | x | x | x | x | x | | | | | | | | | | | | | | | | | | | | | | | | |
| **៩. ផែនការថវិកាសម្រាប់ទ្រទ្រង់សហគមន៍** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៩.១ ភាគទានពីសមាជិកសហគមន៍ | | | | | | | | | | | x | | | | | | | | | | | | x | | | | | | | | | | | | x | |
| ៩.២.ភាគទានប្រចាំឆ្នាំ | | | | | | | | | | | x | | | | | | | | | | | | x | | | | | | | | | | | | x | |
| ៩.៣.ភាគទានពីអ្នកខាងក្រៅឬអ្នកមិនមែនជាសមាជិក | | | | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |

| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៧.ផ្សព្វផ្សាយពីច្បាប់ផលផល និងលិខិតបទដ្ឋានពាក់ ព័ន្ធ និងកសាងសមត្ថភាពគណៈកម្មការសហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧.១.ផ្សព្វផ្សាយពីច្បាប់ផលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧.១.១.ផ្សព្វផ្សាយពីច្បាប់ផលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ | | | x | | | x | | | x | | | x | | | x | | | x | | | x | | | x | | | x | | | x | | | x | | | x |
| ៧.១.២.ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង | | | | x | | | | x | | | | x | | | | x | | | | x | | | | x | | | | x | | | | x | | | | x |

សូមគោរពជូន

លោកចៅសង្កាត់ក្របីរៀល

"ដើម្បីជូនពិនិត្យនិងសម្រួល"

ថ្ងៃ............ខែ..........ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

..........., ថ្ងៃទី២៨ ខែ..........ឆ្នាំ២០១៩

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

លេខៈ..........

បានឃើញនិងគោរពជូន

លោកនាយសង្កាត់រដ្ឋបាលជលផលផ្សារលើ

"ដើម្បីជូនពិនិត្យនិងសម្រួល"

ថ្ងៃ............ខែ..........ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ក្របីរៀល, ថ្ងៃទី២៨ ខែ.......... ឆ្នាំ២០១៩

**លោកចៅសង្កាត់ក្របីរៀល**

**យ៉ុន យ៉ែម**

បានឃើញនិងគោរពជូន

លោកនាយផ្នែករដ្ឋបាលជលផលចុងឃ្នៀស

"ដើម្បីជូនពិនិត្យនិងសម្រួល"

ថ្ងៃ............ខែ..........ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ផ្សារលើ, ថ្ងៃទី២៨ ខែ.......... ឆ្នាំ២០១៩

**នាយសង្កាត់រដ្ឋបាលជលផលផ្សារលើ**

បានឃើញនិងគោរពជូន

លោកនាយខណ្ឌរដ្ឋបាលជលផលសៀមរាប

"ដើម្បីជូនពិនិត្យនិងសម្រួល"

ថ្ងៃ............ខែ..........ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ចុងឃ្នៀស, ថ្ងៃទី២៨ ខែ.......... ឆ្នាំ២០១៩

**នាយផ្នែករដ្ឋបាលជលផលចុងឃ្នៀស**

លេខៈ..........

បានឃើញនិងគោរពជូន

លោកប្រធានមន្ទីរ

កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តសៀមរាប

"ដើម្បីជូនពិនិត្យនិងសម្រួល"

ថ្ងៃ............ខែ..........ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

សៀមរាប, ថ្ងៃទី..........ខែ..........ឆ្នាំ២០១៩

**នាយខណ្ឌរដ្ឋបាលជលផលសៀមរាប**

**ចាន់ តុង**

លេខៈ..........

បានឃើញនិងគោរពជូន

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

"ដើម្បីជូនពិនិត្យនិងសម្រេចដោយអនុគ្រោះ"

ថ្ងៃ............ខែ..........ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

សៀមរាប, ថ្ងៃទី..........ខែ..........ឆ្នាំ២០១៩

**ប្រធានមន្ទីរ**

**កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តសៀមរាប**

**អនុប្រធាន**

**ប៉ែន ប៊ុនធឿន**

លេខៈ..........

បានឃើញនិងឯកភាព

ថ្ងៃ............ខែ..........ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី..........ខែ..........ឆ្នាំ២០១៩

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**